ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ
# បឹង បានទី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០១២- ២០១៤)

| | | | |
|---|---|---|---|
| ឈ្មោះសហគមន៍នេសាទ : | | បឹងបានទី | |
| ភូមិ | : បន្ទាយយមរាជ | ឃុំ | :ប្រាសាទ |
| ភូមិ | : ស្អាង | ឃុំ | : កំពង់ថ្ម |
| ស្រុក | : សន្ទុក | និង | |
| ភូមិ | : បន្ទាយចាស់ | ឃុំ | : ត្នោតជុំ |
| ស្រុក | : បារាយណ៍ | | |
| ខេត្ត | : កំពង់ធំ | | |

# ផែនការគ្រប់គ្រង

# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៏នេសាទ**បឹងបានទី**មានទីតាំងស្ថិតនៅក្នុងភូមិចំនួនបី គឺភូមិបន្ទាយយមរាជ ឃុំប្រាសាទ និងភូមិស្ពាង ឃុំកំពង់ថ្ម ស្រុកសន្ទុក និងភូមិបន្ទាយចាស់ឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដែលមាន៤០៤គ្រួសារស្មើនិងសមាជិកសរុបចំនួន៥១០នាក់ ស្រីចំនួន ២២៣ នាក់ និងមានគណៈកម្មការសហគមន៏ចំនួន ១១ នាក់ ស្រីចំនួន ០៤ នាក់។

សហគមន៏នេសាទនេះត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី២០ខែកុម្ភៈឆ្នាំ២០០៧និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៏រវាងការិយាល័យនេសាទខេត្តនិងសហគមន៍នេសាទចុះថ្ងៃ ទី ២៤ខែ មេសា ឆ្នាំ ២០០៧ ។

កន្លងមកសហគមន៏នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ

-បានបើកមហាសន្និបាតកំណើតដំបូង បោះឆ្នោតជ្រើសរើសគណៈកម្មការ និងបែងចែកតួនាទី ភារៈកិច្ចគណៈកម្មការ សហគមន៏នេសាទ

-បានរៀបចំក្រុមល្បាតបានចំនួន ០២ ក្រុម និងធ្វើការចុះល្បាតជាប្រចាំ

-បានពិគ្រោះយោបល់ធ្វើលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៏នេសាទ

- បានបោះបង្គោលព្រំប្រទល់កន្លែងសហគមន៍នេសាទចំនួន ១៣០ដើម ទៅតាមយាមការនៃផែនទីសហគមន៏នេសាទ

-បានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៏ជាមួយខណ្ឌរដ្ឋបាលជលផល

-បានចុះបញ្ជីសមាជិកភាពសហគមន៏នេសាទ និងប្រមូលប្រាក់ភាគទានប្រចាំឆ្នាំបានចំនួន ៥០ភាគរយ នៃសមាជិកសរុប

-បានផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៏នេសាទ ផែនទីកន្លែងនេសាទសហគមន៏ កិច្ចព្រមព្រៀង កន្លែងនេសាទសហគមន៏

-បានផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីផលប៉ះពាល់នៃការប្រើប្រាស់ថ្នាំពុល សារៈប្រយោជន៏ព្រៃលិចទឹក និងផ្សព្វផ្សាយច្បាប់ស្តីពីជលផល

-គណៈកម្មការសហគមន៏នេសាទបានប្រជុំប្រចាំខែរៀងរាល់ ០១ ខែម្តង។

-បានរៀបចំកន្លែងអភិរក្សត្រីមេពូជ ចំនួន ២កន្លែង និង បោះបង្គោល ៣៧ ដើម ដាក់លូ ២០លូ គល់ ៧៥ គល់។

- រៀបចំក្រុមសន្សំប្រាក់ ចំនួន ៣ក្រុម ។

-ក្រុមចិញ្ចឹមមាន១៨គ្រួសារ ។

-ក្រុមចិញ្ចឹម ជ្រូក ១៣ គ្រួសារ ។

-កន្លែងបង្កាត់ពូជត្រី ១កន្លែង ។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ១-ប្រជាពលរដ្ឋ:

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន ៣២៣៥ នាក់ប្រុស១៥៤៥ នាក់ស្រី ១៦៩០ នាក់ គឺ ជនជាតិខ្មែរមួយរយភាគរយ។
- ចំនួនស្ត្រីមេម៉ាយ ១២១ នាក់
- ចំនួនជនពិការ ២៥ នាក់ ស្រី ១២ នាក់
- ចំនួនចាស់ជរា ៣៩ នាក់ ស្រី ២៦ នាក់
- ចំនួនកុមារកំព្រា ១៧នាក់ ស្រី ០៦ នាក់
- ចំនួនអ្នកមានជំងឺរាំរៃ ១៩ នាក់ ស្រី ១១ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ ៨០ ភាគរយ និងកាតូលិក ២០ភាគរយ ។
- កំរតវប្បធម៌នៃមាជិកសហគមន៍នេសាទទាំងអស់មានអ្នកមិនចេះអក្សរមានចំនួន ៧៥ នាក់ ស្រី ៤៣ នាក់ រៀនត្រឹមកម្រិតបឋមសិក្សាចំនួន ៨០៥ នាក់ ស្រី ៥១២ នាក់ កំរិតមធ្យមសិក្សាចំនួន ៣១២ នាក់ ស្រី ១៣០ នាក់ និងកំរិត ឧត្តមសិក្សាចំនួន ៦០ នាក់ ស្រី ២៧ នាក់។

**-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍រួមមានៈ

- ធ្វើនេសាទចំនួន ១២៨០ នាក់
- ធ្វើស្រែចំនួន ១៣១៤ នាក់ ក្នុងទំហំផ្ទៃដីស្រែ ៨៥០ ហិកតា
- ធ្វើវារីវប្បករចំនួន ១៨ គ្រួសារ ទំហំ ១ ហិកតា (ចិញ្ចឹមត្រីក្នុងស្រះ)
- ដាំបន្លែចំនួន ២៦០ គ្រួសារ ក្នុងទំហំផ្ទៃដី ១០ ហិកតា
- ជាងផ្ទះចំនួន ១២ គ្រួសារ
- ធ្វើចំការចំនួន ២៨០ គ្រួសារ ក្នុងទំហំផ្ទៃដី ២០ ហិកតា
- ធ្វើសិប្បករចំនួន ៦គ្រួសារ
- លក់ដូរចំនួន ៣៩ គ្រួសារ
- ប្រមូលទិញផលនេសាទ ០៦ គ្រួសារ
- ចិញ្ចឹមសត្វលក្ខណៈគ្រួសារ ៦០០ គ្រួសារ
- រត់ម៉ូតូឌុប ១៥ គ្រួសារ
- រត់តាក់ស៊ី ០៥គ្រួសារ
- ឡើងត្នោត ៩៥ គ្រួសារ
- ស៊ីឈ្នួល ១៥០០ នាក់
- ពេទ្យសត្វ ០៤ នាក់
- គ្រូពេទ្យ១ ០ នាក់
- ឆ្មបភូមិ ០៣ នាក់

- ជាងជួសជុលម៉ាស៊ីន ០៨ នាក់
- ផ្សារដែក ០៤ នាក់
- ជាងកាត់សក់ ០៩ នាក់
- ជាងកាត់ដេរ ១១ នាក់
- គ្រូបុរាណ ១២ នាក់
- កម្មកររោងចក្រ ២៥០ នាក់
- សំអាងការ ០៥ នាក់
- សត្វឃាត ០៣ គ្រួសារ
- លក់ចំណីសត្វ ០២ គ្រួសារ ។

**កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

**ទីតាំង**

កន្លែងនេសាទសហគមន៍ **បឹងបានទី** ជាដែននេសាទទឹកសាបមានលក្ខណៈជាបឹង កន្លែងនេសាទបំរុង ទឹកសាប មានទំហំ ៦២ ហិកតា និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ :

- ខាងជើងទល់នឹងផ្លូវរទេះភូមិបន្ទាយយមរាជ
- ខាងត្បូងទល់នឹងដីស្រែភូមិស្លាង
- ខាងកើតទល់នឹងដីស្រែភូមិព្រៃភ្នួរ
- ខាងលិចទល់នឹងស្រែតាអន

**ដែននេសាទ**

កន្លែងនេសាទសហគមន៍ **បឹងបានទី** មានបឹងចំនួន ០១ និងព្រៃលិចទឹកនៅជុំវិញមាត់បឹង

- បឹងបានទី ទំហំ ២២,៤ ហិចតា នេសាទពីខែ ០១ ដល់ខែ ១២
- ព្រៃលិចទឹកមានទំហំសរុប ២២,៨ ហិកតា
- ព្រៃរេចរឹលត្រូវស្តារ ឬជួសជុលឡើងវិញនៅតំបន់ទួលចាម ទំហំ ១៣ ហិកតា
- ព្រៃរេចរឹលត្រូវស្តារ ឬជួសជុលឡើងវិញនៅតំបន់កំពង់អុស ទំហំ ០៣ ហិកតា
- ព្រៃរេចរឹលត្រូវស្តារ ឬជួសជុលឡើងវិញនៅតំបន់ខាងជើងបាង ទំហំ ០,៧ ហិចតា ។

**តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

- អន្លង់បាងបឹងបានទី ទំហំ ២,២៥ ហិកតា ( បណ្តោយ ១៥០ម ទទឹង ១៥០ម)
- អន្លង់រូងក្រពើ ទំហំ ០១ ហិកតា ( បណ្តោយ ១០០ម ទទឹង ១០០ម)
- ព្រៃទួលចាម ទំហំ ៥,០៣ ហិកតា ។

៥. ធនធានផលផល

ប្រភេទត្រី ៖

ត្រីរស់-ឆ្តោរ-រៀល-ស្លាត-ឆ្លាំង-ត្រីអំពិលទុំ-ចង្វាមូល-ក្លាំងហាយ-ប្រា-ក្រម៉ម-អណ្តែង-ចង្វា-កំភ្លាញ-ឆ្លូញ-ក្រាញ់-ខ្ទាន់-ឆ្ពិន-ក្រសែង-កន្ធប់-ដំរី-កញ្ចុះ-ក្រុស-ផ្ទោង-កញ្ចាញ់ច្រាស់-កញ្ច្រូក-កាហែរ-កំភ្លាវ-លិញ-ត្រនេល-សណ្តាយ-ក្រាយ-ច្រឡឹង-ព្រលូង-ស្លឹកឬស្សី-កំពត-អន្ទង់ ។ល ។

ប្រភេទវារីសត្វផ្សេងៗ ៖

ក្តាម-ខ្យង-ខ្ចៅ-គ្រុំ-លៀស-អណ្តើក-កន្លាយ-ពស់-កំពិស-កង្កែប-ហ៊ីង-គីង្គក់-កន្ទាទូក-កន្ធេះឡង់ ។ល ។

ប្រភេទសត្វស្លាបទឹក៖

កុកស-កុកក្រក-មាន់ទឹក-មាន់ទោល-ទោម-ប្រវឹក-ខ្ទុំ-ទាព្រៃ-វនាលខ្យង-ក្រសា-ត្រដក់-ក្អែកទឹក-ស្មោញ-អក-អែអូត-ក្អែកគោក-ក្រ ។ល ។

ប្រភេទសត្វ ៖

ស្វា-ភេ-ខ្លាត្រី ។

ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ៖

ដើមរាំង-ភ្នំភ្លេង-អញ្ចាញ-ត្រស់-សណ្តាន់-បបួយ-តាអូរ-ត្រឡក-ខ្ទុំ-ល្បៀង-ទៀនព្រៃ-ធ្មើមអណ្តើក-ខ្នាយមាន់-កណ្តប់ចង្កេរ-ស្លែង-ញរ-សាច់ពៅ-ប្រផេញ-វល្លិប្រេង-ឈ្លើយ-ល្ពាក់-ផ្តៅទឹក-វល្លិដូងព្រះ-វល្លិតាអើក-កំផ្លោក-កំពីញពួយ-ចក-ស្មោ-ត្រកួន-កញ្ឆែត-រាបច្រាំ-សារ៉ាយ-ក្រចាប់-ព្រលិត-រំចង់ ។

៦. ការធ្វើនេសាទ

ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៤៤៥ នាក់ ស្រី ២០៣ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទដែលរស់នៅក្នុងសហគមន៍មានចំនួន ៥៧០ នាក់ ស្រី ១៩៧ នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ២៥ នាក់ ស្រី ០ នាក់ ។
- ខ. ឧបករណ៍នេសាទ

ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ, ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ.......ដល់ ខែ........) |
|---|---|---|---|---|
| មង | ដៃ (៥០ម) | ៥២០ (២៨x២៦០៖) | ក្រឡា=២-៣,៥ហ៊ុន<br>សំរុង=២,៥ម<br>ប្រវែង=២៦០០០ម | ខែ១ - ខែ ១២ |

| | | | | |
|---|---|---|---|---|
| សន្ទូចរនង | ផ្លែ | ២៦០០០<br>(១០០ផ x ២៦០ន) | ផ្លែលេខ១៤-១៨ | ខែ១ - ខែ ១២ |
| សំណាញ់ | វង់ | ៥០<br>(៥០ន x ១វង់) | ក្រឡា=២-៣ហ៊ុន<br>សំរុង=៨ហាត់ | ខែ១ - ខែ ១២ |
| លបទល់ | គ្រឿង | ៥០<br>(៥ន x ១០គ) | ទំហំ=0,៤0x១,២0ម<br>ចន្លោះគ្រៀម=៣ហ៊ុន | ខែ១ - ខែ ១២ |
| លបត្រីដីរ | គ្រឿង | ៥០<br>(៥ន x ១០គ) | ទំហំ=0.៤0x១.២0ម<br>ចន្លោះគ្រៀម=៣ហ៊ុន | ខែ១ - ខែ ១២ |
| លបលូង | គ្រឿង | ២៤០<br>(៨ន x ៣០គ) | ទំហំ=0.៤0 x ១.២0ម<br>ចន្លោះគ្រៀម=១,៥-២ហ៊ុន | ខែ១ - ខែ ១២ |
| លាន់ | គ្រឿង | ១០<br>(១នx១០គ) | | ខែ១ - ខែ ១២ |
| ប៉ោង | គ្រឿង | ២៤០<br>(១២ន x ២០គ) | | ខែ១ - ខែ ១២ |
| បង្កៃ | ផ្លែ | ៣០<br>(៣នx១០ផ) | ផ្លែលេខ១៤-១៨ | ខែ១ - ខែ ១២ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកកំរោលភ្ជាប់មាស៊ីនជជុះ | ២០ គ្រឿង | ៣០០-៦០០គក្រ | ៥-១១ សេះ |
| ទូកអុំឬ ចែវ | ៥០ គ្រឿង | ១៥០-៣០០គក្រ | |

**- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ:**

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ, ប្រវែង | រដូវប្រើប្រាស់ឧបករណ៍<br>(ខែ.......ដល់ ខែ........) |
|---|---|---|---|---|
| មង | ដៃ<br>(៥០ម) | ៥២០<br>(២ន x២៦០ន) | ក្រឡា=២-៣,៥ហ៊ុន<br>សំរុង=២,៥0ម<br>ប្រវែង=២៦០០០ម | ខែ១ - ខែ ១២ |
| សន្ទូចរនង | ផ្លែ | ១២០០<br>(១០០ផ x ១២ន) | ផ្លែលេខ ១៤-១៦ | ខែ១ - ខែ ១២ |
| សំណាញ់ | វង់ | ៥០វង់ | ក្រឡា=២-២,៥ហ៊ុន | ខែ១ - ខែ ១២ |
| លបទល់ | គ្រឿង | ៥០ | ទំហំ=0,៤0 x 0,៨0ម | ខែ១ - ខែ ១២ |

| | | | | |
|---|---|---|---|---|
| | | (៥ន x ១០គ) | ចន្លោះត្រៀម ១,៥ហ៊ុន | |
| លបត្រីដីវ | គ្រឿង | ៥០<br>(៥ន x ១០គ) | ទំហំ=០,៤០ x ០,៨០ម<br>ចន្លោះត្រៀម១,៥ហ៊ុន | ខែ១ - ខែ ១២ |
| លបលួង | គ្រឿង | ២៤០<br>(៨ន x ៣០គ) | ទំហំ=(០,៤០-០,៨០)<br>ចន្លោះត្រៀម១,៥-២ហ៊ុន | ខែ១ - ខែ ១២ |
| លាន់ | គ្រឿង | ១០<br>(១នx១០គ) | | ខែ១ - ខែ ១២ |
| ប៉ោង | គ្រឿង | ២៤០<br>(១២ន x ២០គ) | | ខែ១ - ខែ ១២ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកកំរោលភ្ជាប់មាស៊ីនជជុះ | ១០ គ្រឿង | ៥០០-៦០០គក្រ | ៥-១១ សេះ |
| ទូកអុំឬ ចែវ | ៥០ គ្រឿង | ១៥០-២៥០គក្រ | |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ, ប្រវែង | រដូវប្រើប្រាស់ឧបករណ៍<br>(ខែ.......ដល់ ខែ........) |
|---|---|---|---|---|
| មង | ដៃ<br>(៥០ម) | ៦<br>(២ន x៣ន) | ក្រឡា=២,៥-៣,៥ហ៊ុន<br>សំរុង=២,៥ម<br>ប្រវែង=៣០០ម | ខែ១ - ខែ ១២ |
| សន្ទូចរនង | ផ្លែ | ៨០០<br>(២០០ផ x៤ន) | ផ្លែលេខ១៤-១៨ | ខែ១ - ខែ ១២ |
| សំណាញ់ | វង់ | ១<br>(១ន x ១វង់) | ក្រឡា=២-៣ហ៊ុន<br>សំរុង=៨ហាត់ | ខែ៦ - ខែ ៩ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកកំរោលភ្ជាប់មាស៊ីនជជុះ | ២៥ គ្រឿង | ៥០០-៦០០គក្រ | ៥-៩ សេះ |
| ទូកអុំឬ ចែវ | ៥ គ្រឿង | ១៥០-២៥០គក្រ | |

**ឆ.ជាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ**

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៦០ គក្រ | ១០៥ គក្រ | ១៦៥ គក្រ |
| ក្តាម ខ្យង | ០៤ គក្រ | ០៥ គក្រ | ០៩ គក្រ |
| សរុប | ៦២ គក្រ | ១១០ គក្រ | ១៧៤ គក្រ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទ **បឹងបានទី** មានទស្សនៈវិស័យរួម គឺចូលរួមគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយ សមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

### ខ. គោលបំណងរួម

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប និងនាទីព្រៃលិចទឹកនៅជុំវិញបឹងបានទី ជាកន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជា ប្រពៃណី ។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព ធ្វើឱ្យធនធានធម្មជាតិក្នុងតំបន់បានសម្បូរឡើងវិញ និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ច្បាស់ និងចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

**គោលបំណង:**

- គ្រប់គ្រងធនធានជលផលឱ្យបានសមស្រប និងធ្វើឱ្យប្រសើរឡើងវិញនូវធនធានជលផលនៅក្នុងកន្លែងនេសាទ សហគមន៍
- កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ និងកាត់បន្ថយទំនាស់នៅក្នុងកន្លែងនេសាទសហគមន៍
- បង្កើនការយល់ដឹងពីការគ្រប់គ្រងធនធានជលផលនៅក្នុងតំបន់គ្រង់គ្រងដោយសហគមន៍នេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវកាលនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុង កន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ...ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន(ក្នុង១ថ្ងៃ) | |
| ...ងបានទី | ខែ១- ខែ១២ | មង | ក្រឡា=២.៥ហ៊ុនឡើង ប្រវែង=៤០០ម | ៤ន=៤០០ម | ១ន=១០០ម |
| | | ប៉ោង | | ៤ន=៤០គ | ១ន=១០គ |
| | | លាន់ | | ៤ន=៤០គ | ១ន=១០គ |
| | | អង្រុត | | ១០ន=១០គ | ១ន=១គ |
| | | សន្ទូច | ២១០ផ្លែ ផ្លែលេខ ១៤-១៨ | ៣ន=២១០ផ | ១ន=៧០ផ |
| | | ប្របក់ | ៥ផ្លែ | ៥ន=៥ផ | ១ន=១ផ |
| | | | ផ្លែលេខ ..(ផ្លែច្វៃ)........ | | |
| | | បង្កៃ | ៣០ផ្លែ ផ្លែលេខ ១៤-១៨ | ៣ន=៣០ផ | ១ន= ១០ផ |

.២ ផែនការកែលំអដែននេសាទ

**គោលបំណង**

- រក្សាទឹកនៅក្នុងបឹងរបស់សហគមន៍ឱ្យបានច្រើន ជាពិសេសនៅរដូវប្រាំង ដើម្បីឱ្យមានត្រីច្រើនក្នុងបឹងបានទី
- ទាក់ទាញការចូលរួមគ្រប់គ្រងធនធានជលផល និងលើកស្ទួយកម្រិតជីវភាពប្រជាជនក្នុងតំបន់
- ធ្វើឱ្យប្រសើរឡើងវិញនូវធនធានជលផលនៅក្នុង និងជុំវិញបឹងបានទី។

| ឈ្មោះដែននេសាទ | ទំហំ ហ.ត | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ទំនាបស្រែតាហង្ស | ០,៥២ | ៣៥០មx១៥ម x៤ម | -លើកទំបន់បង្ហៀរទឹក (៣៥០x១៥x៤ម) -រកដៃគូ NGOsជួយ -រដ្ឋាភិបាល | ១/២០១៣ | ៣/២០១៣ | |

.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

**គោលបំណង**

- បង្កើនពូជត្រី ឬស្តុកត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សា ការពារព្រៃលិចទឹកនៅជុំវិញ ដែលជាជំរក និងជាប្រភពចំណីធម្មជាតិ

- ផ្សព្វផ្សាយ និងផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋឱ្យចេះស្រឡាញ់ធនធានធម្មជាតិ

- កាត់បន្ថយការនេសាទល្មើសច្បាប់

| ឈ្មោះ/ទីតាំង | ទំហំ ហ.ត | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| អន្លង់អភិរក្សបឹងបានទី | ១៥០មx១៥០ម | -ពូជត្រីគ្រប់ប្រភេទ<br>-សត្វទឹកគ្រប់ប្រភេទ | ជួសជុល បោះបង្គោលនិងបន្ថែមស្លាក ស្លាកសញ្ញាហាម<br>-បន្ថែមលូជំរកត្រីសិប្បនិម្មិត<br>បង្កើនយាមល្បាតជាប្រចាំ<br>-ដាក់ពោងបណ្តែតព្រំប្រទល់កន្លែងអភិរក្ស | ៣/២០១២ | ៤/២០១២ | អង្គការដៃគូរដ្ឋាភិបាល |
| ព្រៃអភិរក្សទួលចាម (ខ្វែកដេក) | ៥ | ព្រៃគ្រប់ប្រភេទ<br>សត្វគ្រប់ប្រភេទ<br>នៅក្នុងតំបន់ | ជួសជុល បោះបង្គោលនិងស្លាកសញ្ញាហាម<br>កាប់ព្រៃលិចទឹក<br>-ចុះល្បាតជាប្រចាំ<br>-ដាក់ពោងបណ្តែតសំគាល់ព្រំប្រទល់តំបន់អភិរក្ស | ២០១២ | ២០១៤ | អង្គការដៃគូរដ្ឋាភិបាល |

### .៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

**គោលបំណង**

- គ្រប់គ្រងព្រៃលិចទឹកឱ្យនៅគង់វង្ស និងបានប្រសើរឡើង

- ផ្តល់ឱកាស និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រងធនធានធម្មជាតិ

- កាត់បន្ថយការកាប់បំផ្លាញ និងប្រើប្រាស់ព្រៃលិចទឹកក្នុងតំបន់គ្រប់គ្រងដោយសហគមន៍។

| ឈ្មោះ/ទីតាំង | ទំហំ ហ.ត | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| កំពង់អុស | ៣ | ត្រស់ ម្តេញ ត្រសែង រាំង ភ្នំភ្លេង អញ្ចាញ សណ្តាន់ | ជុសជុលកូនឈើ ដែលខូច - ផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃលិចទឹក -ជួសជុលស្លាកសញ្ញាហាមការកាប់ព្រៃលិចទឹក | ២០១២ | ២០១៤ | សុំជំនួយជាសំភារៈ និងថវិកា អង្គការនានា |
| ទូលចាម | ១៣ | ត្រស់ ម្តេញ តាំសែង រាំង ភ្នំភ្លេង អញ្ចាញ សណ្តាន់ | ជុសជុលកូនឈើ ដែលខូច - ផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃលិចទឹក -ជួសជុលស្លាកសញ្ញាហាមការកាប់ព្រៃលិចទឹក | ២០១២ | ២០១៤ | សុំជំនួយជាសំភារៈ និងថវិកា អង្គការនានា |
| ខាងជើងបាង | ០,៧ | ត្រស់ ម្តេញ តាំសែង រាំង ភ្នំភ្លេង អញ្ចាញ សណ្តាន់ | ជុសជុលកូនឈើ ដែលខូច - ផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃលិចទឹក -ជុសជុលស្លាកសញ្ញាហាមការកាប់ព្រៃលិចទឹក | ២០១២ | ២០១៤ | សុំជំនួយជាសំភារៈ និងថវិកា អង្គការនានា |

**ត.៥ ផែនការបែងចែកតំបន់គ្រប់គ្រងព្រៃលិចទឹកតាមភូមិនីមួយៗ**

| **ទីតាំង** | **ទំហំ ហ.ត** | **សកម្មភាព** | **ចាប់ផ្តើម** | **បញ្ចប់** | **អ្នកទទួលខុសត្រូវ** |
|---|---|---|---|---|---|
| ពីចំណុចអូរត្រស់ខាងជើងបឹង ដល់ចំណុចស្រែតាសំ | ៦,៦៨ (តាមមាត់បឹងក្នុងដែននេសាទសហគមន៍) | -ឃ្លាំមើល -ថែទាំ | ២០១២ | ២០១៤ | ភូមិបន្ទាយយមរាជ |
| ពីចំណុចស្រែតាសំខាង | ៦,៣២ | -ឃ្លាំមើល | ២០១២ | ២០១៤ | ភូមិបន្ទាយចាស់ |

| | | | | | |
|---|---|---|---|---|---|
| [illegible] | (តាមខាត់បឹង ក្នុងដែនទេសាទ សហគមន៍) | -ថៃទាំ | | | |
| [illegible] | ៦.៨១ ហិកតា (តាមខាត់បឹង ក្នុងដែនទេសាទ សហគមន៍) | -ឃ្លាំមើល<br>-ថៃទាំ | ២០១២ | ២០១៤ | ភូមិស្លាង |

### ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

**គោលបំណង**

- បង្កើនប្រាក់ចំណូលក្នុងគ្រួសារសមាជិកសហគមន៍
- កាត់បន្ថយការចាប់ត្រីពីក្នុងធម្មជាតិ ឬក្នុងដែនទេសាទ
- ផ្សព្វផ្សាយបច្ចេកទេស ជំរុញ និងលើកទឹកចិត្តលើការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ។

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រី (ក្នុងអាងស៊ីម៉ង់ត៍) | ១៤គ្រួសារ (បីភូមិ) | ត្រីអណ្តែងកូនកាត់ | ១៤០០០កូនត្រី | ២០១២ | ២០១២ |
| ចិញ្ចឹមត្រីក្នុងស្រះ | ០៤ គ្រួសារ | ទីឡាព្យា.កាប អណ្តែង | ១០០០០ក្បាល | ២០១២ | ២០១២ |

### ង.៧ ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ

**គោលបំណង**

- បង្កើនប្រាក់ចំណូល និងកែលំអជីវភាពសមាជិកសហគមន៍
- សមាជិកសហគមន៍បានយល់ដឹងពីបញ្ហាសុខភាព អនាម័យ និងការអប់រំបរិស្ថាន
- ពង្រឹងសហគមន៍ និងបង្កើនការយល់ដឹងនៅក្នុងសហគមន៍។

| ប្រភេទកម្មវិធី | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| រៀបចំក្រុមសន្សំ ប្រាក់ ៣ក្រុម(ថ្មី) | -ផ្សព្វផ្សាយគោលការណ៍សន្សំប្រាក់<br>-ចងក្រងក្រុមសន្សំប្រាក់<br>-ដំណើរការសន្សំប្រាក់ និងឥណទាន | ២០១២ | ២០១៤ | ឧបត្ថម្ភដោយ UNDP.GBA. |

| | | | | |
|---|---|---|---|---|
| ...ម្មវិធីទឹកស្អាត សុខភាព ...អនាម័យ | -ផ្សព្វផ្សាយពីការបំពុលបរិស្ថាន និងផលប៉ះពាល់ដល់ការរស់នៅ និងសុខភាព<br>-ផ្សព្វផ្សាយគោលការណ៍ប្រើប្រាស់ទឹកស្អាត<br>-ចងក្រងក្រុម និងការផ្តល់ធុងចំរោះទឹកស្អាត<br>-តាមដានត្រួតពិនិត្យ | ២០១២ | ២០១៤ | សុំជំនួយពីអង្គការនានា សប្បុរសជន |
| ...ចិញ្ចឹមសត្វ ១៥គ្រួសារ | . ផ្សព្វផ្សាយគោលការណ៍<br>.រៀបចំក្រុម<br>.បណ្តុះបណ្តាលបច្ចេកទេស<br>-ត្រួតពិនិត្យ តាមដាន<br>-ផ្តល់ពូជ | ២០១២ | ២០១៤ | ឧបត្ថម្ភដោយ UNDP.GBA.<br>-រកដៃគូ អង្គការនានា |
| ដាំបន្លែ ៤៥គ្រួសា | .ផ្សព្វផ្សាយគោលការណ៍រៀបចំក្រុម<br>.បណ្តុះបណ្តាលបច្ចេកទេស<br>-ត្រួតពិនិត្យ តាមដាន<br>-ផ្តល់ពូជ | ២០១២ | ២០១៤ | ឧបត្ថម្ភដោយ UNDP.GBA.<br>- រកដៃគូ អង្គការនានា |
| ...ច្ចេកទេសស្រែបង្ហាញស្រូវ ...១ដើម | .ផ្សព្វផ្សាយគោលការណ៍<br>.រៀបចំក្រុម<br>.បណ្តុះបណ្តាលបច្ចេកទេស<br>-ត្រួតពិនិត្យ តាមដាន<br>-ផ្តល់ពូជ | ២០១២ | ២០១៤ | ឧបត្ថម្ភដោយ UNDP.GBA.<br>- រកដៃគូ អង្គការនានា |
| ច្ចេកទេសឈើហូបផ្លែ | .ផ្សព្វផ្សាយគោលការណ៍<br>.រៀបចំក្រុម<br>.បណ្តុះបណ្តាលបច្ចេកទេស<br>-ត្រួតពិនិត្យ តាមដាន<br>-ផ្តល់ពូជ | ២០១២ | ២០១៤ | - រកដៃគូ អង្គការនានា |

### ពង្រឹងគណៈកម្មការសហគ[redacted]នៃសាទ

**...បំណង**

- បង្កើនសមត្ថភាពគណៈកម្មការសហគមន៍នេសាទ
- ពង្រឹងសហគមន៍នេសាទ
- មានសាមគ្គីភាព និងទំនាក់ទំនងល្អ ។

| សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|
| ...ារប្រជុំប្រចាំខែ ឬត្រីមាស ...បស់គណៈកម្មការ | ២០១២ | ២០១៤ | -ត្រូវប្រជុំអោយទៀងទាត់<br>-ត្រូវពិភាក្សាអំពីលទ្ធផលការងារ ផែនការអនុវត្តបន្ត ចំណុចខ្លាំង.ខ្សោយក្នុងការគ្រប់គ្រង<br>-ពេលប្រជុំត្រូវធានាការបញ្ចេញមតិស្មើភាពគ្នា |
| ...ារប្រជុំប្រចាំខែ ឬត្រីមាស ជាមួយឃុំ | ២០១២ | ២០១៤ | -រាយការណ៍ពីលទ្ធការងារនិងផែនការអនុវត្តបន្ត<br>-រាយការណ៍ពីបញ្ហាជួបប្រទះ និងសុំអនុសាសន៍ដើម្បីដោះស្រាយ<br>-ស្តាប់របាយការណ៍ឃុំត្រឡប់មកវិញចែករំលែកពត៏មានដល់គណៈកម្មការទាំងអស់ |
| ...ធ្វីកំណត់ហេតុ របាយការណ៍ | ២០១២ | ២០១៤ | -ត្រូវមានកំណត់ហេតុ និងរបាយការណ៍រាល់ពេលចុះប៉េសកកម្ម និងការប្រជុំនានា<br>-ត្រូវធ្វើរបាយការប្រចាំខែ |
| ...ារក្សារទុកឯកសារ | ២០១២ | ២០១៤ | -រាល់ឯកសារទាំងអស់ត្រូវមានតំកល់ទុកនៅសហគមន៏ |
| ...កិច្ចសហការនិ៍ និង ការទំនាក់ទំនង | ២០១២ | ២០១៤ | -ត្រូវបង្កើនកិច្ចសហការ និងការទំនាក់ទំនងជាមួយ អាជ្ញាធរភូមិ ឃុំ សមត្ថកិច្ចជុំនាញ NGOs |
| ...រៀបចំក្រុមល្បាត | ២០១២ | ២០១៤ | -រៀបចំក្រុមល្បាតនៅតាមភូមិនី |

| | | | |
|---|---|---|---|
| | | | មួយៗ<br>-ធ្វើផែនការល្បាត |
| ទស្សនៈកិច្ចសិក្សា | ២០១២ | ២០១៤ | -កសិករគំរូ<br>និងគណៈកម្មការសហគមន៍ឱ្យ<br>អញ្ជើញទៅផ្លាស់ប្តូរបទ<br>ពិសោធន៍ជាមួយសហគមន៍ក្នុង និង<br>ក្រៅខេត្ត |

**ផែនការផ្សព្វផ្សាយ បណ្តុះបណ្តាល បង្កើនការយល់ដឹង**

**គោលបំណង**

- ពង្រឹងសហគមន៍នេសាទ
- បង្កើនសមត្ថភាពគណៈកម្មការសហគមន៍ និងបង្កើនការយល់ដឹងរបស់សមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធ
- សមាជិកសហគមន៍ស្វែងយល់ពីបច្ចេកទេសកសិកម្ម និងបង្កើនមុខរបរ និងបង្កើនប្រាក់ចំណូល
- កាត់បន្ថយបទល្មើសនេសាទនៅក្នុងសហគមន៍នេសាទ។

| ផែនការ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ ប្រមូលផល | ផ្សេងៗ |
|---|---|---|---|---|
| ផ្សព្វផ្សាយ | លក្ខន្តិកៈនិង បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ២០១២ | ២០១៤ | គណៈកម្មការស.ន<br>និងអ្នកសម្របសម្រួល |
| | គោលការណ៍ក្រុមសន្សំប្រាក់ | ២០១២ | ២០១៤ | |
| | សារៈប្រយោជន៍នៃធនធានធម្មជាតិ និងបរិស្ថាន | ២០១២ | ២០១៤ | |
| | ច្បាប់ជលផល និងច្បាប់ផ្សេងៗទាក់ទងដល់ការគ្រប់គ្រងសហគមន៍នេសាទ | ២០១២ | ២០១៤ | |
| | ការគ្រប់គ្រង<br>និងសារៈប្រយោជន៍នៃព្រៃលិចទឹក | ២០១២ | ២០១៤ | |
| | ផលប៉ះពាល់ការប្រើប្រាស់ថ្នាំពុលកសិកម្ម<br>និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ | ២០១២ | ២០១៤ | |
| | បច្ចេកទេសចិញ្ចឹមត្រី | ២០១២ | ២០១៤ | |
| | បច្ចេកទេសចិញ្ចឹមសត្វ | ២០១២ | ២០១៤ | |

**គ-១០ ផែនការមរិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍**

**គោលបំណង**

- ពង្រឹងសហគមន៍នេសាទ

- ទទួលបានការគាំទ្រដល់សហគមន៍នេសាទ
- អភិវឌ្ឍសហគមន៍ និងបង្ហាញឱ្យគេឃើញពីឆន្ទៈរបស់សហគមន៍នេសាទមូលដ្ឋាន។

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានប្រចាំឆ្នាំ | គណៈកម្មការចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | ២០១២ | ២០១៤ | | |
| ជំនួយសប្បុរសជន និងអង្គការនានា | -សរសេគម្រោងស្នើសុំ<br>-ផ្សព្វផ្សាយអោយគេដឹង<br>- ធ្វើហិបប្រាក់វិភាគទានទ្រទ្រង់សហគមន៍នេសាទ | ២០១២ | ២០១៤ | | |
| បដិភាគរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ឃុំ សង្កាត់ | -បញ្ចូលផែនការអភិវឌ្ឍន៍សហគមន៍ ទៅនិងផែនការអភិវឌ្ឍន៍ឃុំ<br>-ស្នើសុំប្រាក់បដិភាគពីឃុំដើម្បីអនុវត្តផែនការសហគមន៍ | ២០១២ | ២០១៤ | | |

### ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ ត្រូវមានយុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តន៍ផែនការរួមមានៈ សមាជិកគណៈ កម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែលមានបទពិសោធន៍ និង ចំណេះដឹងល្អៗ ជាពិសេស អំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ចដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈ ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្ស ជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកា ទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការ ឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តន៍ផែនការ
- រៀបចំកម្មវិធីអនុវត្តន៍ផែនការតាមដំណាក់កាលនីមួយៗអោយជាក់លាក់ និង ច្បាស់លាស់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍ នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តន៍ផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ

- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគ
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ប្រើប្រាស់ឧបករណ៍នេសាទ | -កំណត់កន្លែងនេសាទ<br>-កំណត់ប្រភេទ និងទំហំឧបករណ៍នេសាទ និងចំនួនមនុស្ស ដែលអាចចូលនេសាទបាន ក្នុង ១ថ្ងៃ<br>-ផ្សព្វផ្សាយពីការកំណត់ទំហំឧបករណ៍នេសាទ និងចំនួនមនុស្សដែលអនុញ្ញាតឱ្យចូលនេសាទក្នុងកន្លែងនេសាទនីមួយ ៗ ដល់សមាជិកសន. និងអ្នកមកពីខាងក្រៅ<br>-ចុះត្រួតពិនិត្យ តាមដានជាប្រចាំ | -ផលត្រីអាចកើនឡើង និងអាចកាត់បន្ថយបាននូវការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ក្នុងដែនសន.<br>-អ្នកនេសាទនៅក្នុងកន្លែងសន.គ្រប់គ្រង នឹងអាចយល់ដឹងពីការគ្រប់គ្រងរបស់សន. | -ចំណាយលើការត្រួតពិនិត្យ និងតាមដាន ប្រមាណ៥០០.០០០ រៀល ក្នុង១ឆ្នាំ | -ភាគទានសន.<br>និងសប្បុរសជន<br>-អង្គការនានា | ២០១២ | ២០១៤ | |
| ២. កែលំអដែននេសាទ | -លើកទំនប់បង្វែរទឹកនៅត្រង់ទំនាបស្រែតាហង្សប្រវែង ៣៥០ម ទទឹង ១៥ម និងកំពស់ ៤ម ដើម្បីទប់ទឹកបឹង | -អាចរក្សាទឹកបានច្រើនគ្រប់គ្រាន់នៅក្នុងបឹង និងសម្បូរត្រី និងសត្វគ្រប់ប្រភេទ<br>-សមាជិកសហគមន៍ | -ចំណាយលើការសាងសង់ ១៥០០០ដុល្លាអាមេរិក | -រដ្ឋាភិបាល<br>-សប្បុរសជន<br>-អង្គការនានា | ២០១៣ | ២០១៣ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | -អនុវត្តលើកទំនប់ដោយគ្រឿងចក្រ ឬដោយ<br>-រៀបចំក្រុមការងារទទួលខុសត្រូវតាមដានការអនុវត្តន៍ ត្រួតពិនិត្យ និងជួសជុលជាប្រចាំ | ទទួលផលប្រយោជន៍ពីការប្រើប្រាស់ទឹក និងធនធានធម្មជាតិ ជាពិសេសត្រីមេពូជកើនឡើង | | | | | |
| ៣. កំណត់ និងរៀបចំកន្លែងអភិរក្ស | - កន្លែងអភិរក្សជួសជុលបោះបង្គោលកំណត់ ព្រំប្រទល់<br>-បោះស្លាកសញ្ញា និងការហាមឃាត់<br>-ផ្សព្វផ្សាយកន្លែងអភិរក្ស<br>-ដាក់ជំរកសប្បនិម្មិត<br>-រៀបចំក្រុមល្បាត និងតាមដានជាប្រចាំ | -កន្លែងអភិរក្សត្រីពូជចំនួន ២កន្លែង និងព្រៃអភិរក្ស ១កន្លែង នឹងមានបង្គោលថ្មីជួសជុលបន្ថែមអន្លង់អភិរក្សបាងបឹង បានទី (១៥០ម គុណ ១៥០ម) ព្រៃអភិរក្សខ្ទែកដេក (ទួលចាម) ៥ហត.<br>-កន្លែងអភិរក្សទាំងអស់ នឹងត្រូវបានបោះបង្គោលថ្មី និងស្លាកសញ្ញាហាមឃាត់ប្រភេទនៅក្នុងតំបន់ | -ជួសជុលបង្គោលព្រំប្រទល់និងស្លាកសញ្ញាថ្មី ១០០០០០០ រៀល ផ្សព្វផ្សាយ និងយាមល្បាត ៥០០០០០ រៀល ក្នុង ១ឆ្នាំ | -រដ្ឋាភិបាល<br>-អង្គការនានា<br>-សប្បុរសជន | ២០១២ | ២០១២ | |
| ៤. ថែរក្សាព្រៃលិចទឹក | -ជួសជុលនិងថែរក្សាព្រៃឡើង | -ប្រភេទព្រៃលិចទឹកចំនួន ០៧ ប្រភេទ | ៥០០០០០ រៀលក្នុង ១ឆ្នាំ | -សហគមន៍នេសាទ<br>-រដ្ឋាភិបាល | ២០១២ | ២០១៤ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | -ផ្សព្វផ្សាយពីការ ប្រយោជន៍ព្រៃលិចទឹកជាសាធារណៈ ។ | គឺនៅ តំបន់កំពង់អុស ទួលចាម និងតំបន់ខាងជើងបាង គ្រប់គ្រងបានល្អ និងមានការចូលរួមយ៉ាងផុលផុស | | | | | |
| ៥. បែងចែកតំបន់គ្រប់គ្រងព្រៃលិចទឹក | -រៀបចំបែងចែកតាមភូមិដើម្បីទទួលខុសត្រូវគ្រប់គ្រង និងការពារព្រៃលិចទឹកចំនួន ៣ កន្លែង មានទំហំសរុប ២២,៨១ ហាត.<br>-ភូមិនីមួយៗ គឺ ភូមិបន្ទាយយមរាជ បន្ទាយចាស់ និងភូមិស្ពាង ត្រូវបែងចែកឱ្យទទួលខុសត្រូវគ្រប់គ្រង ការពារ និងថែរក្សាព្រៃលិចទឹកដែលមានស្រាប់តាម | -ព្រៃលិចទឹកដែលមានស្រាប់នៅជុំវិញបឹងបានទី នឹងត្រូវបានការពារបានត្រឹមត្រូវ<br>-ត្រី និងវារីសត្វគ្រប់ប្រភេទ នឹងសម្បូរឡើងវិញនៅក្នុងសន.<br>-មានការលើកទឹកចិត្តឱ្យមានការចូលរួមក្នុងសន.កាន់តែច្រើនឡើង | -ចំណាយ ៣០០០០០ រៀល ក្នុង១ឆ្នាំ | -ភាគទានសមាជិកសន.<br>-ស្ថាប័នជំនាញ<br>-អង្គការនានា<br>-សប្បុរសជន | ២០១២ | ២០១៤ | ចូលរួមផ្ទាល់ដោយគណៈកម្មការសន. និងសមាជិកសន. |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | តបនរៀង១ខ្លួន<br>-ភូមិនីមួយៗត្រួតពិនិត្យតាមដាន និងទប់ស្កាត់ការកាប់បំផ្លាចព្រៃលិចទឹកជាប្រចាំ | | | | | | |
| ៦-អភិវឌ្ឍន៍វារីវប្បកម្ម | -ផ្សព្វផ្សាយបច្ចេកទេសពីការចិញ្ចឹមត្រីក្នុងអាងតូចៗស្រះដល់សមាជិកស.ន<br>-ចងក្រងក្រុមអ្នកចិញ្ចឹម ត្រី<br>-ត្រួតពិនិត្យ និងតាមដាន | -សមាជិកសន.ចំនួន ១៨ គ្រួសារ នឹងអភិវឌ្ឍការចិញ្ចឹមត្រីនៅក្នុងអាងតូចៗតាមគ្រួសារក្នុងសន.<br>-កូនត្រីអណ្តែង និងទីឡាព្យា កាប់ចំនួន២ ៤០០០ក្បាល នឹងត្រូវបានគេចិញ្ចឹមនៅក្នុងសន.<br>-សមាជិកចំនួន ៧ គ្រួសារ និងអភិវឌ្ឍន៍កាត់បន្ថយតាមរយៈការអភិវឌ្ឍន៍ចិញ្ចឹមត្រីតាមគ្រួសារក្នុងសន.<br>-បង្កើនប្រាក់ចំណូល | -ចំណាយលើការផ្សព្វផ្សាយ និងតំលៃកូនត្រី៣៣៨០០០០ រៀល | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សហគមន៍នេសាទ | ២០១២ | ២០១២ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | គ្រួសារ | | | | | |
| ៧- អភិវឌ្ឍន៍កម្មវិធីចម្រុះ | -បង្កើតក្រុមសន្សំប្រាក់<br>-ចងក្រងជាក្រុមដើម្បីអនុវត្តកម្មវិធីទឹកស្អាត<br>-សុខភាព និងអនាម័យដើម្បីអនុវត្តជាគំរូនៅក្នុងសន.<br>ចិញ្ចឹមសត្វ ការសាងសង់ទ្រុង សម្រាប់ចិញ្ចឹម<br>-ផ្សព្វផ្សាយ និងតាមដានការអនុវត្តគ្រប់សកម្មភាព<br>-សមាជិករៀបច្បាដាំបន្លែដោយខ្លួនឯង | -សមាជិកសន.ប្រមាណ ៤៥ អាចបង្កើនប្រាក់ចំណូលតាមរយៈសកម្មភាពសន្សំប្រាក់<br>-សុខភាពរបស់សមាជិកសន. នឹងបានប្រសើរឡើង និងអាចកាត់បន្ថយភាពក្រីក្របានមួយកំរិត<br>-សមាជិកចំនួន ៤៥ គ្រួសារ បានទទួលបច្ចេកទេសសំរាប់ចិញ្ចឹមបរិស្ថាន និងផលប៉ះពាល់ដល់ការរស់នៅ និងសុខភាពគ្រួសារ<br>-សមាជិកមានច្បាដាំបន្លែគ្រប់ៗគ្នា | -សម្រាប់ការផ្សព្វផ្សាយ បណ្តុះបណ្តាលនិងផ្តល់តាមដាន ប្រមាណ ៦០០០ដុល្លា ។ | -ឧបត្ថម្ភដោយ UNDP.GBA | ២០១២ | ២០១៤ | |
| ៨-ពង្រឹងគណៈកម្មការសហគមន៍នេសាទ | -បណ្តុះបណ្តាលចំណេះដឹងផ្នែករដ្ឋបាល និងការគ្រប់គ្រងសន. | -គណៈកម្មការសន. យល់ដឹងពីរបៀបរៀបចំទុកដាក់ឯកសារសន.នឹង | -ការចំណាយលើសម្ភារៈផ្សេងៗ ផ្សព្វផ្សាយ | -ឧបត្ថម្ភដោយ UNDP.GBA | ២០១២ | ២០១៤ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | -រៀបចំក្រុមល្បាត<br>សម្ភារៈល្បាត<br>និងឃ្លាំមើលដែន<br>នេសាទសហគមន៍<br>-រៀបចំបណ្ណាញសន.<br>-ទស្សនៈកិច្ចសិក្សាផ្លាស់<br>ប្តូរបទពិសោធន៍ | ណ៏ កំណត់ហេតុ<br>-<br>គណៈកម្មការសហគមន៍<br>នេសាទចេះយកផែនការ<br>សហគមន៍បញ្ចូលផែនក<br>ារអភិវឌ្ឍន៍របស់ឃុំ<br>សមាហរន្តកម្មនិងលិខិត<br>ស្នាមផ្សេងៗ<br>-គណៈកម្មការសន.នឹង<br>ចេះដោះស្រាយទំនាស់<br>នៅក្នុងសន. មានជំនាញ<br>សម្របសម្រួល និងចេះ<br>សរសេរសំណើស្នើសុំ<br>ថវិកា<br>-នឹងមានការយាម<br>ល្បាត និងមានផែនការ<br>ល្បាតត្រឹមត្រូវក្នុង<br>កន្លែងនេសាទសហគមន៍<br>សកម្មភាពល្មើសក្នុង<br>ដែននេសាទសន.នឹង | ដុល្លាអាមេរិក<br>-ទស្សនៈកិច្ចសិក្សា<br>ផ្លាស់ប្តូរបទពិសោធន៍<br>២000000 រៀល | -រដ្ឋាភិបាល<br>-អង្គការនានា<br>-សប្បុរសជន | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | អប្បរិមា<br>-ការប្រមូលព័ត៌មានក្នុងសន. និងទទួលព័ត៌មានផ្សេងៗពីខាងក្រៅទាន់ពេលវេលា និងសន.ចេះធ្វើការងារជារបៀបបណ្តាញ។<br>-សន.នឹងអាចផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមករវាងសន. និងសន.ក្នុងការអនុវត្តគ្រងគ្រងសន. | | | | | |
| ៩-ផ្សព្វផ្សាយ បណ្តុះបណ្តាល បង្កើនការយល់ដឹង | -ផ្សព្វផ្សាយការគ្រប់គ្រងសន. និងផលប៉ះពាល់ពីការប្រើប្រាស់ថ្នាំពុលកសិកម្ម និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់<br>-បណ្តុះបណ្តាលបច្ចេកទេសបណ្តុះកូន | -សមាជិកសហគមន៍ប្រមាណពី ៧០-៨០% យល់ដឹងពីការគ្រប់គ្រងសន. លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ច្បាប់ជលផល និងច្បាប់ផ្សេងៗទាក់ទងនឹងការគ្រប់គ្រងធនធាន | -ចំណាយសរុប ១០០០០០០ រៀល ក្នុង ១ឆ្នាំ | -រដ្ឋាភិបាល<br>-អង្គការនានា | ២០១២ | ២០១៤ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ព្រៃលិចទឹក<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី ចិញ្ចឹមសត្វ និងការផលិត និងប្រើប្រាស់ជីសរីរាង្គ | -សមាជិកសហគមន៍នឹងទទួលបានបច្ចេកទេស និងបទពិសោធន៍ថ្មីៗ ទាក់ទងនឹងវិស័យកសិកម្ម | | | | | |
| ១០-ថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | -ប្រមូលភាគទានប្រចាំឆ្នាំ<br>-ស្វែងរកថវិកាពីរដ្ឋាភិបាល សប្បុរសជន និងអង្គការនានា | -សមាជិកសន.១០០% នឹងបង់ប្រាក់សមាជិកភាព<br>-ប្រមាណ ៨០% នៃអ្នកដែលពាក់ព័ន្ធនឹងដែននេសាទសន. នឹងត្រូវបានប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ<br>-ថវិកាមួយចំនួននឹងត្រូវបានផ្តល់សម្រាប់ទ្រទ្រង់សន.ដោយអង្គការនានា រដ្ឋាភិបាល និងសប្បុរសជន | ៥០០០០០ រៀល សម្រាប់ការអនុវត្ត និងផ្សព្វផ្សាយ | -រដ្ឋាភិបាល<br>-អង្គការនានា<br>-សប្បុរសជន<br>-សមាជិកសន. និងអ្នកពាក់ព័ន្ធ | ២០១២ | ២០១៤ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ...៥០០០០០ រៀល នឹងត្រូវប្រមូលបានពីការប្រមូលភាគទានក្នុង ១ឆ្នាំ | | | | | |

## តារាងកម្មវិធីការងារ

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១២ | | | | | | | | | | | | ២០១៣ | | | | | | | | | | | | ២០១៤ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **១. ការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.១ កំណត់កន្លែងនេសាទ ប្រភេទ និង ទំហំឧបករណ៍នេសាទ | | | | | | → | → | → | | | | | | | | | → | → | → | → | | | | | | | | | | → | → | → | → | | | |
| ១.២ ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | → | → | | | | | | | | | | | | → | → | | | | | | | | | | | → | → | → | | | | | | | | |
| ១.៣ ត្រួតពិនិត្យតាមដាន | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| **២.កំណត់ និង រៀបចំកន្លែងអភិរក្ស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.១ ជួសជុល បោះបង្គោលនៃ្លងអភិរក្ស | | | → | → | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.២ បោះស្លាកសញ្ញាហាមឃាត់ | → | → | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.៣ ផ្សព្វ ផ្សាយ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| ២.៤ ដាក់ពោងបណ្ដែតសំគាល់ | → | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.៥យាល្បាតនិងតាមដានជាប្រចាំ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| **៣.កែលំអរដែននេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| |
|---|
| ៣.១ លើកទំនប់បង្ស៊ូរ ប្រវែង ៣៥០មទទឹង ១៥មកំពស់៤ម នៅទំនាបស្រែតាហង្ស |
| ៣.២ រៀបចំទទួលខុសត្រូវ តាមដាន ការអនុវត្ត ត្រួតពិនិត្យ ជួសជុល និង ថែទាំជាប្រចាំ |
| **៤.ថែរក្សាព្រៃលិចទឹក** |
| ៤.១ត្រួតពិនិត្យនិងតាមដាន |
| ៤.២ បែងចែកតំបន់គ្រប គ្រង ព្រៃលិចទិក ទៅតាមភូមិនិមួយៗ |
| ៤.៣ រៀបចំស្លាកបោះសញ្ញាទៅ តាមតំបន់និមួយៗ |
| ៤.៤ ផ្សព្វផ្សាយជាសាធារណៈ |
| **៥.ការអភិវឌ្ឍន៍វារីវប្បកម្ម** |
| ៥.១ បណ្តុះបណ្តាល និង ផ្សព្វផ្សាយ បច្ចេកទេសចិញ្ចឹមត្រី |
| ៥.២ ចងក្រងក្រុមចិញ្ចឹមត្រី |
| ៥.៣ ត្រួតពិនិត្យតាមដាន |
| **៦.ការអភិវឌ្ឍន៍កម្មវិធីចំរុះ** |
| ៦.១បង្កើតនិងចងក្រងក្រុមសន្សំប្រាក់ឡើងវិញ |

| | |
|---|---|
| ៦.២ រៀបចំផងក្រុមកម្មវិធីទឹក ស្អាត សុខភាពនិង អនាម័យ | |
| ៦.៣ បណ្តុះបណ្តាលបច្ចេកទេសដាំបន្លែ | |
| ៦.៤ បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ស្រូវ ១ដើម | |
| ៦.៥ បណ្តុះបណ្តាលបច្ចេកទេសឈើហូបផ្លែ | |
| ៦.៦ បណ្តុះបណ្តាលបច្ចេកទេសដល់ក្រុមចិញ្ចឹមសត្វ | |
| ៦.៧ ផ្សព្វផ្សាយពីការគ្រប់គ្រង ស.ន (លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង) | |
| **៧.ពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ** | |
| ៧.១ បណ្តុះបណ្តាលចំណេះដឹងផ្នែករដ្ឋបាល និង គ្រប់គ្រង | |
| ៧.២ រៀបចំក្រុមល្បាត | |
| ៧.៣រៀបចំបណ្តាញ | |
| ៧.៤រៀបចំទស្សនៈកិច្ចសិក្សា | |

| | |
|---|---|
| ៧.៥ ផ្សព្វផ្សាយបង្កើនការយល់ដឹង និងការគ្រប់គ្រងសហគមន៍ | |
| **៨.ថវិការទ្រទ្រង់សហគមន៍** | |
| ៨.១ ប្រមូលវិភាគទានប្រចាំឆ្នាំពីសមាជិក | |
| ៨.២ការស្វែងរកថវិការ | |

ថ្ងៃទី ២១ ខែ ១១ ឆ្នាំ ២០១១

**គណៈកម្មការសហគមន៍នេសាទ**

ការី ប៉ុង

**បានឃើញ និង បញ្ជូនមក**

លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ

" ដើម្បីសូមមេត្តាពិនិត្យ-សំរួល "

ថ្ងៃទី...២២... ខែ...១១.......ឆ្នាំ២០១១

នាយសង្កាត់រដ្ឋបាលជលផលស្រុកសន្ទុក

**កែវ_សុខា**

**បានឃើញ**

ថ្ងៃទី២១........ខែ..១១..............ឆ្នាំ២០១១

មេឃុំ...

ឡាត់.សឿន

លេខ......ខ.រ.ជ.ក.ធ

បានឃើញ និង គោរពជូន

ឯកឧត្តមនាយអធិការដ្ឋានរដ្ឋបាលជលផលខាងជើងបឹងទន្លេសាប

" ដើម្បីសូមមេត្តាពិនិត្យ-សំរួល "

កំពង់ធំ ថ្ងៃទី ០៤ ខែ ០១ ឆ្នាំ២០១២

**នាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ**

**ប៉ែន_វណ្ណារ៉ា**

លេខ:.........អ.រ.ជ

បានឃើញ និង គោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា

ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

" ដើម្បីសូមមេត្តាពិនិត្យ-សម្រេចដោយអនុគ្រោះ "

កំពង់ធំ ថ្ងៃទី ២៣ ខែ ០១ ឆ្នាំ២០១២

**នាយអធិការដ្ឋានរដ្ឋបាលជលផលខាងជើងបឹងទន្លេសាប**

ឆាន់ ឌីវ៉ាន់នី

លេខ ១០៤៥ ជ.ជ

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ...ឆ្នាំ២០១២

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុក**

**ប្រធានរដ្ឋបាលជលផល**

**ណៅ_ធួក**